# ស្ថានទូតអូស្ត្រាលី
# រាជធានីភ្នំពេញ

## សេចក្តីប្រកាសព័ត៌មាន

## ការប្រកាសជ្រើសរើសនិស្សិតអាហារូបករណ៍អូស្ត្រាលីឆ្នាំ២០១៣

ឯកអគ្គរាជទូតអូស្ត្រាលី **លោកជំទាវ ផេននី រីឆាដស៍** នឹងប្រកាសជាផ្លូវការនូវការជ្រើសរើសនិស្សិតអាហារូបករណ៍អូស្ត្រាលីឆ្នាំ២០១៣ ព្រមទាំងធ្វើការស្វាគមន៍ដល់និស្សិតកម្ពុជាដែលទើបបញ្ចប់ការសិក្សាពីប្រទេសអូស្ត្រាលីប្រកបដោយជោគជ័យ ហើយបានវិលត្រលប់មកកាន់មាតុប្រទេសវិញកាលពីពេលថ្មីៗកន្លងមក ដែលកម្មវិធីនេះនឹងប្រារព្ធឡើងនៅឯសណ្ឋាគារសូហ្វីថែល នៅថ្ងៃទី៥ មីនា។ កម្មវិធីនេះនឹងមានការចូលរួមពីសំណាក់មន្រ្តីជាន់ខ្ពស់កម្ពុជា ដៃគូអភិវឌ្ឍន៍ ព្រមទាំងតំណាងមកពី វិស័យឯកជន សង្គមស៊ីវិល និង អតីតនិស្សិតដែលធ្លាប់បានទៅសិក្សានៅប្រទេសអូស្ត្រាលី។ **ឯកឧត្តម ជា សុផារ៉ា** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ នឹងចូលរួមថ្លែងសន្ទរកថានៅក្នុងពិធីនេះផងដែរ។

ក្នុងឆ្នាំ២០១៣នេះ អាហារូបករណ៍ចំនួន**៥៥កន្លែង** នឹងផ្តល់ជូនដល់និស្សិតកម្ពុជា ដើម្បីទៅសិក្សាថ្នាក់បណ្ឌិតឬ បរិញ្ញាប័ត្រជាន់ខ្ពស់នៅប្រទេសអូស្ត្រាលី។ បេក្ខជនឆ្នើមដែលភាពលេចធ្លោនឹងអាចប្រកួតប្រជែងទៅសិក្សានៅកម្មវិធីសំរាប់ភាពជាអ្នកដឹកនាំ ដែលផ្តល់ឱកាសអោយនិស្សិតទាំងនោះបានចូលរួមនៅក្នុងវេទិកា និងបណ្តាញសំរាប់ភាពជាអ្នកដឹកនាំ រួមជាមួយក្រុមនិស្សិតអាហារូបករណ៍អូស្ត្រាលីសំរាប់ភាពជាអ្នកដឹកនាំ មកពីបណ្តាប្រទេសនានាជុំវិញពិភពលោក។ លើសពីនេះទៀត យើងនៅមានកម្មវិធីអាហារូបករណ៍អូស្ត្រាលីសំរាប់កិច្ចប្រឹងប្រែងប្រកបដោយជោគជ័យ (Endeavour Awards) ដែលឧបត្ថម្ភដល់ការសិក្សារយៈពេលវែង ឬខ្លី ការស្រាវជ្រាវ និងការអភិវឌ្ឍន៍វិជ្ជាជីវៈនៅប្រទេសអូស្ត្រាលីតាមរយៈកម្មវិធីសិក្សាផ្សេងៗជាច្រើន។

រដ្ឋាភិបាលអូស្ត្រាលីបានប្តេជ្ញាលើកកំពស់វិស័យសិក្សាធិការថ្នាក់ឧត្តមសិក្សានិង ការកសាងសមត្ថភាពធនធានមនុស្សនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ និស្សិតកម្ពុជាសរុបប្រមាណជាង៥០០នាក់ បានទទួលអាហារូបករណ៍សំរាប់ការសិក្សាថ្នាក់ក្រោយឧត្តមនៅប្រទេសអូស្ត្រាលី

ចាប់តាំងពីឆ្នាំ១៩៩៤មក។ នៅមានសិក្ខាកាមកម្ពុជាជិត២០០នាក់ផ្សេងទៀត ដែលបានទៅសិក្សាវគ្គបណ្តុះបណ្តាលនិង កសាងសមត្ថភាពនៅប្រទេសអូស្ត្រាលីក្រោមកម្មវិធីអាហារូបករណ៍អូស្ត្រាលីរយៈពេលខ្លីសំរាប់ភាពជាអ្នកដឹកនាំ (ALAF) ចាប់តាំងពីឆ្នាំ២០០៦មក។

អាហារូបករណ៍អូស្ត្រាលីផ្តល់ឱកាសដោយមិនរើសអើង ហើយបើកចំហដោយស្មើភាពសំរាប់ស្ត្រីនិង បុរស ឬបេក្ខជនមកពីតាមបណ្តាខេត្តនានាឬ ទីក្រុង និងជនពិការ។ បេក្ខជន ដែលជាជនពិការ អាចមានឱកាសទទួលបាននូវជំនួយបន្ថែមសំរាប់ការសិក្សាប្រសិនបើចាំបាច់។ អាហារូបករណ៍នេះបើកសំរាប់ថ្នាក់ក្រោយឧត្តមសិក្សា ដែលផ្តោតទៅលើផ្នែក សុខាភិបាល កសិកម្មនិងអភិវឌ្ឍន៍ជនបទ ហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធច្បាប់និងយុត្តិធម៌ ព្រមទាំង ធនធានរ៉ែនិងថាមពល ការចរចារពាណិជ្ជកម្ម សមភាពយ៉េនឌ័រ ប្រសិទ្ធិភាពនៃជំនួយ ពិការភាព និងការការពារកុមារ។

អាហារូបករណ៍អូស្ត្រាលីកំពុងបើកទទួលពាក្យ ហើយនឹងបិទនៅថ្ងៃ ៣០មេសា ២០១៣។

អាហារូបករណ៍អូស្ត្រាលីសំរាប់កិច្ចប្រឹងប្រែងប្រកបដោយជោគជ័យ (Endeavour Award) នឹងបើកទទួលពាក្យពីថ្ងៃ ០១ មេសា ដល់ ៣០ មិថុនា ២០១៣។

**ព័ត៌មានលំអិតសំរាប់អ្នកសារព័ត៌មានដែលមានបំណងចង់ចូលរួម**

*កាលបរិច្ឆេទ៖ ថ្ងៃអង្គារ៍ ទី ៥ ខែ មីនា ឆ្នាំ ២០១៣ ពីម៉ោង ១៧៣០ ដល់ ២០៣០*

*ទីតាំង៖ សណ្ឋាគារ សូហ្វីតែល ភ្នំពេញ*

ព័ត៌មានលំអិតស្តីពីអាហារូបករណ៍អូស្ត្រាលីសូមចូលទៅកាន់ www.australiaawards.gov.au

ទំនាក់ទំនងសម្រាប់សារព័ត៌មាន

**លោក បេនចាមីន នីកូល** (Benjamin Nichols) លេខាទី២, benjamin.nichols@dfat.gov.au

ស្ថានទូតអូស្ត្រាលីភ្នំពេញ

ទូរស័ព្ទលេខ ០២៣ ២១៣ ៤៧០

ភ្នំពេញ ថ្ងៃទី ៤ មីនា ២០១៣